លេខ ១៤ ចេញផ្សាយថ្ងៃទី១ ខែសីហា ឆ្នាំ២០២២

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែកក្កដា ឆ្នាំ២០២២

**និយ័តករបរធនបាលកិច្ច**

**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**

**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២២

នាព្រឹកថ្ងៃសុក្រ ៣កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២២ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាននាយកដ្ឋានកិច្ចការគ តិយុត្តនិងអធិការកិច្ច និងនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ។ កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមិថុនា ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។

## មាតិកា


- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងទិសដៅការងារប្រចាំខែកក្កដាឆ្នាំ២០២២ ទំព័រទី១
- កិច្ចប្រជុំពិភាក្សាលើការបន្ថែមសមាសភាពដឹកនាំការងារក្របខណ្ឌក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ទំព័រទី២
- កិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២២ ទំព័រទី២
- កម្មវិធីសប្បុរសធម៌នៅវិទ្យាស្ថានអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈ (LCDI) ទំព័រទី៣
- កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ទំព័រទី៣
- កិច្ចប្រជុំពិភាក្សារវាង **ន.ប.ធ.** ជាមួយវិទ្យាស្ថាន China-ASEAN Information Harbor Institute of Big Data Research (CAIHIBDR) នៃសាកលវិទ្យាល័យក្វាងស៊ី ប្រទេសចិន ទំព័រទី៤
- កិច្ចពិភាក្សាអំពីការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យបរធនបាលកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី “ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច” ទំព័រទី៥
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនកររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល (២០២២-២០២៤) និងផែនការសកម្មភាពឆ្នាំ២០២២ របស់និយ័តករបរធនបាលកិច្ច ទំព័រទី៥
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី “ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច” ទំព័រទី៦
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ទំព័រទី៦
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ទំព័រទី៧
- ផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) និងការបូកសរុបសមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ និងទិសដៅការងារបន្ត" ទំព័រទី៧
- កម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ខេត្តសៀមរាប ទំព័រទី៨
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី "បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច" ទំព័រទី៩
- កិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការងារគ្រប់គ្រងគម្រោងស្តីពីគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ទំព័រទី៩
- វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី១ ឆ្នាំ២០២២ ទំព័រទី៩
- កម្មវិធីកិច្ចពិភាក្សា÷ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព សម្រាប់ក្រុមទី១ នៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ ទំព័រទី១០
- ការប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី១ ទំព័រទី១១
- កិច្ចប្រជុំពិភាក្សាការងាររបស់និយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក ទំព័រទី១១




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងទិសដៅការងារប្រចាំខែកក្កដា ឆ្នាំ២០២២ ដឹកនាំដោយឯកឧត្តម **នេន ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធន-បាលកិច្ច

## កិច្ចប្រជុំពិភាក្សាលើការបន្ថែមសមាសភាពដឹកនាំការងារក្របខណ្ឌក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

នាព្រឹកថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួម កិច្ចប្រជុំពិភាក្សាលើការបន្ថែមសមាសភាពដឹកនាំការងារក្របខណ្ឌក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (MEWG) និងក្របខណ្ឌអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពី ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ (NRA) និងយន្តការ រាយការណ៍ពីវឌ្ឍនភាពការងារក្រោមក្របខណ្ឌ NRA ដែលបានប្រព្រឹត្តទៅតាមរយៈប្រព័ន្ធវីឌីអូពីចម្ងាយ។



រូបភាពកិច្ចប្រជុំពិភាក្សាលើការបន្ថែមសមាសភាពដឹកនាំការងារក្របខណ្ឌក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច

## កិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២២

នៅព្រឹកថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

មន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង អគ្គនាយកដ្ឋាន និងនិយ័តករក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈប្រព័ន្ធសន្និសិទវីដេអូពីចំងាយ (Zoom)។




រូបភាពកិច្ចប្រជុំដើម្បីពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងការប៉ាន់ស្មានលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កម្មវិធីសប្បុរសធម៌នៅវិទ្យាស្ថានអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈ (LCDI)

នៅព្រឹកថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) រួមដំណើរដោយឯកឧត្តមអគ្គនាយករង **ឧទ ពិសិដ្ឋ** ឯកឧត្តមអគ្គនាយករង **ណី សាគល** លោក-កញ្ញា ដែលជាប្រធាននាយកដ្ឋាន និងសហការី បានរៀបចំកម្មវិធីសប្បុរសធម៌នៅវិទ្យាស្ថានអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈ (LCDI) ដោយបានពាំនាំនូវអំណោយសប្បុរសធម៌ រួមមាន៖ អង្ករ, ប្រេងឆា, ទឹកស៊ីអ៊ីវ, ទឹកត្រី, ត្រីខ, ស្ករស, អំបិល, សម្ភារៈនិងថ្នាំពេទ្យ និងសម្ភារៈសិក្សាមួយចំនួនទៀត ព្រមទាំងបានចែករំលែកបទពិសោធន៍ជីវិតនិងការងារ, សេចក្តីស្រលាញ់ និងការយកចិត្តទុកដាក់ ក៏ដូចជាការផ្តល់កម្លាំងចិត្តដល់កុមារនៅក្នុង LCDI ដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំរបស់សង្គមនៅថ្ងៃអនាគត។




រូបភាពកម្មវិធីសប្បុរសធម៌នៅវិទ្យាស្ថានអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ និងចរិតលក្ខណៈ (LCDI)

## កិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច

នៅរសៀលថ្ងៃពុធ ៨កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច។




រូបភាពកិច្ចប្រជុំអន្តរនាយកដ្ឋាន ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋាន សញ្ញាសក្តិ សញ្ញាសម្គាល់របស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ច ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សារវាង ន.ប.ធ. ជាមួយវិទ្យាស្ថាន China-ASEAN Information Harbor Institute of Big Data Research (CAIHIBDR) នៃសាកលវិទ្យាល័យក្វាងស៊ី ប្រទេសចិន

នាព្រឹកថ្ងៃសុក្រ ១០ កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញ បានអញ្ជើញជួបពិភាក្សាការងារអំពីលទ្ធភាពក្នុងការបង្កើតកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌបច្ចេកទេស ផ្លាស់ប្តូរព័ត៌មាន ចែករំលែកបទពិសោធន៍ និងការកសាងសមត្ថភាពទៅលើបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុ និងធុរកិច្ច ជាមួយវិទ្យាស្ថាន China-ASEAN Information Harbor Institute of Big Data Research (CAIHIBDR) នៃសាកលវិទ្យាល័យក្វាងស៊ី ប្រទេសចិន ដោយមានការចូលរួមពីលោក Fan Zuojun អនុប្រធានសាកលវិទ្យាល័យក្វាងស៊ី និងជាព្រឹទ្ធបុរសនៃវិទ្យាស្ថាន CAIHIBDR កញ្ញា Chen Yaowen សាស្ត្រាចារ្យអមនៃមហាវិទ្យាល័យសេដ្ឋកិច្ច នៃសាកលវិទ្យាល័យហៃណាន និងជាព្រឹទ្ធបុរសនៃវិទ្យាស្ថាន CAIHIBDR កញ្ញា Zhang Jie ព្រឹទ្ធបុរសនៃវិទ្យាស្ថាន CAIHIBDR អមដោយសហការី។ តាមរយៈកិច្ចប្រជុំនេះ ភាគីទាំងពីរបានព្រមព្រៀងធ្វើសហប្រតិបត្តិការក្នុងក្របខណ្ឌបច្ចេកទេស តាមរយៈ ការចុះអនុស្សរណៈយោគយល់គ្នា (MoU)។




រូបភាពកិច្ចប្រជុំពិភាក្សារវាង **ន.ប.ធ.** ជាមួយវិទ្យាស្ថាន China-ASEAN Information Harbor Institute of Big Data Research (CAIHIBDR) នៃសាកលវិទ្យាល័យក្វាងស៊ី ប្រទេសចិន ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច

## កិច្ចពិភាក្សាអំពីការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យបរធនបាលកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃសុក្រ ១០ កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តម **ណី សាគល** អគ្គនាយករង និងលោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងមន្ត្រីជំនាញ បានទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក Don Hsieh និងថ្នាក់ដឹកនាំក្រុមហ៊ុន Phnom Penh Fintech Investment (PPFI) ដើម្បីពិភាក្សាអំពីការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកាលានុវត្តភាពវិនិយោគនៅក្នុងវិស័យបរធនបាលកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយក ក៏ដូចជាភាគីខាងក្រុមហ៊ុន បានផ្លាស់ប្តូរ និងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកលើកិច្ចដំណើរការអភិវឌ្ឍន៍ កាលានុវត្តភាព ក្របខណ្ឌគតិយុត្ត ផ្នែកបច្ចេកទេស និងជាពិសេសផ្នែក FINTECH ផងដែរ។



កិច្ចពិភាក្សាអំពីការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងកាលានុវត្តភាពវិនិយោគ នៅក្នុងវិស័យបរធនបាលកិច្ច ក្នុងព្រះរាជាណាចក្រកម្ពុជា

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃចន្ទ ១៣កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" តាមរយៈប្រព័ន្ធអនឡាញ ZOOM ដោយមានការអញ្ជើញចូលរួមពីលោក **ច្រឹក សុខនិម** ប្រធានសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា និងសមាជិក-សមាជិកា ព្រមទាំងមានការចូលរួមពី ប្រតិបត្តិករបរធនបាល និងភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងវិស័យបរធនបាលកិច្ចផងដែរ ដែលមានអ្នកចូលរួមសរុបច្រើនជាង ១០០ នាក់។ គោលបំណងនៃកិច្ចពិភាក្សានេះ គឺដើម្បីទទួលបានមតិយោបល់ ក៏ដូចជាធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ជាពិសេសអ្នកអនុវត្តការងារផ្ទាល់ ដើម្បីឱ្យសេចក្តីព្រាងប្រកាសខាងលើកាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយសំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមនៅក្នុងវិស័យបរធនបាលកិច្ច។



រូបភាពកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"២០២២ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនកររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល (២០២២-២០២៤) និងផែនការសកម្មភាពឆ្នាំ២០២២ របស់និយ័តករបរធនបាលកិច្ច

នាព្រឹកថ្ងៃអង្គារ ១៤កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់សវនកររបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល (២០២២-២០២៤) និងផែនការសកម្មភាពឆ្នាំ២០២២ របស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាងប្រកាស ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុ

## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃពុធ ១៥កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ លោក **ឃុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញ បានចូលរួមកម្មវិធី "បញ្ជ្រាបការយល់ដឹងស្តីពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS តាមរយៈប្រព័ន្ធសន្និសីទវីដេអូ ដោយប្រើប្រាស់កម្មវិធី Zoom ក្នុងគោលបំណងផ្តល់នូវមូលដ្ឋានមួយចំនួនជូនដល់អង្គភាពថវិកាដែលត្រៀមប្រើប្រាស់ប្រព័ន្ធ FMIS នៅក្នុងឆ្នាំ២០២៣ ខាងមុខ ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់ចូលរួមអនុវត្តសកម្មភាពផ្សេងៗទៀតជាមួយក្រុមការងារ FMIS។



រូបភាពកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "ការទទួលស្គាល់ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប**

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ។ កិច្ចប្រជុំនេះមានការចូលរួមពីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋាន។ ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។

កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការទូទៅ ដឹកនាំដោយ ឯកឧត្តម **ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច

នារសៀលថ្ងៃព្រហស្បតិ៍ ១រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **ឈឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធន-បាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពី ប្រធាននាយកដ្ឋានស្តីទី, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចទាំងអស់។ ជាមួយគ្នានេះ ឯកឧត្តមអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារបន្តផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាពកិច្ចប្រជុំបូកសរុបការងារប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២២ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ដឹកនាំដោយ ឯកឧត្តម **ឈឹ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច។

## ផែនការអភិវឌ្ឍន៍ស្ថាប័ននៃ ន.ប.ធ. សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) និងការបូកសរុបសមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ និងទិសដៅការងារបន្ត"

នាព្រឹកថ្ងៃចន្ទ ៥រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងក្របខណ្ឌនៃការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុង **ន.ប.ធ.** ស្តីពី "ផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) និងការបូកសរុបសមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ និងទិសដៅការងារបន្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាននៃ **ន.ប.ធ.** ដែលបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ២០២២ នៅសណ្ឋាគារ អ៊ីមប្រេសអង្គរ ខេត្តសៀមរាប។



រូបភាពសិក្ខាសាលាស្តីពី "ផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) និងការបូកសរុបសមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ និងទិសដៅការងារបន្ត"



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពសិក្ខាសាលាស្តីពី "ផែនការអភិវឌ្ឍន៍ស្ថាប័ននៃ **ន.ប.ធ.** សម្រាប់រយៈពេល ៥ ឆ្នាំ (២០២១-២០២៥) និងការបូកសរុបសមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ និងទិសដៅការងារបន្ត" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច

## កម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហាសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ខេត្តសៀមរាប

នៅរសៀលថ្ងៃអង្គារ ៦រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) រួមដំណើរដោយឯកឧត្តម **នង ពិសិដ្ឋ**, ឯកឧត្តម **ឈឺ សាកល** អគ្គ-នាយករងនៃ **ន.ប.ធ.** លោក **យុន វាសនា**, លោក **ប៉ូ សំអាង**, កញ្ញា **ឈាន សុខារី**, លោក **ហាយ សុវណ្ណា** ដែលជាថ្នាក់ដឹកនាំនាយកដ្ឋាន និងសហការីនៃ **ន.ប.ធ.** បានរៀបចំកម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហាសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ខេត្តសៀមរាប ដោយបានពាំនាំនូវអំណោយសប្បុរសធម៌ រួមមាន៖ អង្ករ, ប្រេងឆា, ទឹកស៊ីអ៊ីវ, ទឹកត្រី, ត្រីខ, ស្ករស, អំបិល, សម្ភារៈនិងថ្នាំពេទ្យ និងសម្ភារៈសិក្សាមួយចំនួនទៀត ព្រមទាំងបានផ្តល់សេចក្តីស្រលាញ់, សេចក្តីសង្ឃឹម, ការយកចិត្តទុកដាក់, ការចែករំលែកនូវបទពិសោធន៍ជីវិតនិងការងារ ក៏ដូចជាផ្តល់កម្លាំងចិត្តដល់កុមារនៅក្នុងមជ្ឈមណ្ឌល SCC ដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំរបស់សង្គមនៅថ្ងៃអនាគត។



រូបភាពកម្មវិធីសប្បុរសធម៌នៅមជ្ឈមណ្ឌលសហាសង្គ្រោះកម្ពុជា (Salvation Centre Cambodia-SCC) ខេត្តសៀមរាប



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី "បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ៩រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តម **នន ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** និងលោក-កញ្ញាប្រធាននាយកដ្ឋាន បានដឹកនាំមន្ត្រីជំនាញប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី "បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច" ក្នុងគោលបំណងប្រមូលធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធនានា រួមមាន៖ តំណាងនៃនិយ័តករក្រោមឱវាទនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, តំណាងក្រុមហ៊ុនបរធនបាលនិងក្រុមបរធនបាល និងតំណាងមកពីក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសក្នុងវិស័យមូលបត្រ ដើម្បីធ្វើឱ្យសេចក្តីព្រាងប្រកាសនេះមានលក្ខណៈពេញលេញ គ្រប់ជ្រុងជ្រោយ និងទទួលបានទំនុកចិត្តបន្ថែមទៀតពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច ដែលកិច្ចប្រជុំនេះបានប្រព្រឹត្តទៅតាមរយៈប្រព័ន្ធអនឡាញពីចំងាយ (Zoom)។




រូបភាពកិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី "បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចបរធនបាលកិច្ច" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច។

## កិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការងារគ្រប់គ្រងគម្រោងស្តីពីគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)

នារសៀលថ្ងៃសុក្រ ៩រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាប្រធានគ្រប់គ្រងគម្រោង អមដោយសហការី បានចូលរួមកិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការងារគ្រប់គ្រងគម្រោងស្តីពីគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) តាមរយៈប្រព័ន្ធ Zoom ជាមួយតំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (GDICDM), ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) លោក Takeshi Ueda និងលោកស្រី Marishka Etrata ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ម៉ី ម៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជានាយកគម្រោង។




រូបភាពកិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការងារគ្រប់គ្រងគម្រោងស្តីពីគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ម៉ី ម៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជានាយកគម្រោង។

## វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី១ ឆ្នាំ២០២២

នាព្រឹកថ្ងៃចន្ទ ១២ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធន-បាលកិច្ចលើកទី១ ក្រុមទី១ ឆ្នាំ២០២២"។ ការរៀបចំវគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចនេះ គឺជាការបោះជំហានថ្មីបន្ថែមមួយទៀតក្នុងដំណើរការបង្កើតអត្ថិភាពទីផ្សារបរធនបាលកិច្ចពេញលេញនៅកម្ពុជា ដែលមានប្រតិបត្តិករ តួយ៉ាងដូចជា ក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គលឯករាជ្យ បុគ្គលិកជាន់ខ្ពស់ និងបុគ្គល

ផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ជាអ្នកមានគុណវុឌ្ឍិគ្រប់គ្រាន់ តាមលក្ខខណ្ឌតម្រូវក្នុងបទប្បញ្ញត្តិជាធរមាន និងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ។ កម្មវិធីនេះនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥-២៧ ខែកក្កដា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)។




រូបភាពប្រកាសបើក វគ្គបណ្តុះបណ្តាល និងប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី ១ ក្រុមទី១ ឆ្នាំ២០២២ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច។

## កម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព សម្រាប់ក្រុមទី១ នៃកម្មវិធីវគ្គបណ្តុះ-បណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២

កាលពីរសៀលថ្ងៃពុធ ១៤ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមធ្វើជាអ្នកសម្របសម្រួលក្នុងកម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុ-វត្តភាព សម្រាប់ក្រុមទី១ នៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)។ កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយ វាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច និងវិស័យហិរញ្ញវត្ថុ រួមមាន៖ លោកបណ្ឌិត **អ៊ិន ចាន់នី** ប្រធានក្រុមប្រឹក្សាបរធនបាល នៃបរធនបាលកិច្ចហិរញ្ញវត្ថុ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់, លោក **ជា ផល្លារិន** ប្រធានគណៈកម្មការបរធនបាល នៃបរធនបាលកិច្ចហិរញ្ញវត្ថុ អម្រឹត និង ឯកឧត្តម **ស៊ុម សុខម្ភ** ស្ថាបនិកក្រុមហ៊ុន Thurawadh Co. Ltd។ នៅក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយស បានធ្វើការចែករំលែកអំពីបទពិសោធន៍ក្នុងការគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច អត្ថប្រយោជន៍នៃការបង្កើតវិស័យបរធនបាលកិច្ច និងបញ្ហាប្រឈមដែលធ្លាប់បានជួបប្រទះក្នុងការអនុវត្តការងារកន្លងមក ព្រមទាំងបានចែករំលែកអំពីទស្សនវិស័យអំពីវិស័យបរធនបាលកិច្ចផងដែរ។ វាគ្មិនទាំងអស់សុទ្ធតែបានបង្ហាញទស្សនាទានវិជ្ជមានចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ជាពិសេសប្រតិបត្តិការបរធនបាលកិច្ច ដែលបាននិងកំពុងក្លាយជាយន្តការក្នុងបង្កើត និងបង្កើនទំនុកចិត្ត គាំពារដល់លំហូរប្រតិបត្តិការមូលធន និងចូលរួមជំរុញការអភិវឌ្ឍវិស័យពាក់ព័ន្ធផ្សេងៗក្នុងសេដ្ឋកិច្ច និងសង្គមកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពកម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព សម្រាប់ក្រុមទី១ នៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងសម្រាប់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២

## ការប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី១

ការប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី១ដែលបានប្រព្រឹត្តទៅនៅព្រឹកថ្ងៃព្រហស្បតិ៍ ១៥ រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)។



រូបភាពនៃការប្រឡងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី១ ឆ្នាំ២០២២ សម្រាប់ក្រុមទី១

## កិច្ចប្រជុំពិភាក្សាការងាររបស់និយ័តករបរធនបាលកិច្ចជាមួយក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក

នាព្រឹកថ្ងៃសុក្រ ១ កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ ឯកឧត្តម **ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** លោក **ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានទទួលជួបប្រជុំពិភាក្សាការងារជាមួយលោក Kevin Tang ប្រធានក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំក្រុមហ៊ុន Asia Money Fintech Company និងលោក Kevin Chang ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក ដើម្បីពិភាក្សាអំពីការអភិវឌ្ឍ កាលានុវត្តភាព និង FinTech ក្នុងវិស័យបរធនបាលកិច្ច ក៏ដូចជាគំនិតផ្តួចផ្តើមមួយចំនួនក្នុងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាពកិច្ចប្រជុំពិភាក្សាការងាររបស់និយ័តករបរធនបាលកិច្ច ជាមួយក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក ក្រោមការដឹកនាំរបស់ ឯកឧត្តម **ឈី សារគល** អគ្គនាយករងនៃ និយ័តករបរធនបាលកិច្ច



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888